អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩**

# សេចក្តីប្រកាសព័ត៌មាន
# អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលឃុំខ្លួន អៀង សារី បណ្តោះអាសន្ន

នៅក្នុងសេចក្តីសម្រេចដែលបានចេញនៅថ្ងៃនេះ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពន្យារពេលឃុំខ្លួន អៀង សារី បណ្តោះអាសន្ន និងបានច្រានចោលសំណើរបស់ជនត្រូវចោទសុំឲ្យឃុំខ្លួននៅក្នុងផ្ទះ ជំនួសឲ្យការឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង។ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះរួចមក អៀង សារី អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នរហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។

អៀង សារី ដែលកាន់តួនាទីជារដ្ឋមន្ត្រីក្រសួងការបរទេស នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម (សំណុំរឿងនេះស្ថិតក្រោមការស៊ើបអង្កេតនៅឡើយ)។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយបន្ទាប់មក ត្រូវបានដាក់ឲ្យស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្ន សម្រាប់រយៈពេលមួយឆ្នាំដំបូង តាមរយៈដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន សម្រាប់រយៈពេលអតិបរមាមួយឆ្នាំ (រហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩)។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនបដិសធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ននេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ននេះនៅតែជាការចាំបាច់ ដើម្បីទប់ស្កាត់ជនត្រូវចោទពីការរត់គេចខ្លួន។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការឃុំខ្លួននេះគឺចាំបាច់ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

សេចក្តីសង្ខេបនៃសេចក្តីសម្រេចនេះ ត្រូវបានអានជូនដោយប្រធានអង្គបុរេជំនុំជម្រះ ឯ.ឧ ប្រាក់ គឹមសាន នៅក្នុងសវនាការសាធារណៈនាថ្ងៃនេះ។ សំណៅជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះ អាចរកមើលបាននៅលើគេហទំព័រ:
http://www.eccc.gov.kh/english/cabinet/courtDoc/366/C22_5_39_EN.pdf

រូបថតផ្លូវការពីសវនាការថ្ងៃនេះ អាចយកចេញពីគេហទំព័រ:
http://www.eccc.gov.kh/english/cabinet/photo/40/01ISary26June09.jpg
http://www.eccc.gov.kh/english/cabinet/photo/40/02ISary26June09.jpg
http://www.eccc.gov.kh/english/cabinet/photo/40/03ISary26June09.jpg
http://www.eccc.gov.kh/english/cabinet/photo/40/04ISary26June09.jpg

ប្រព័ន្ធផ្សព្វផ្សាយអាចយករូបថតទាំងនេះទៅប្រើប្រាស់ដោយសេរី ប៉ុន្តែ ស្នាដៃរូបថតនេះគួរតែសរសេរថា៖ “*រូបថតផ្តល់ជូនដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*”។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក Lars Olsen
មន្ត្រីផ្នែកទំនាក់ទំនងច្បាប់នៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥ (0) ១២ ៤៨៨ 0២៣
ទូរសព្ទលើតុ +៨៥៥ (0) ២៣ ២១៩ ៨១៤ ext. ៦១៦៩
អ៊ីមែល: olsenl@un.org

លោក រាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ១៥៦
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
អ៊ីមែល: reach.sambath@eccc.gov.kh

លោក ឌីម សុវណ្ណារុំ
មន្ត្រីទទួលបន្ទុកព័ត៌មាននៃ អ.វ.ត.ក
ទូរសព្ទដៃលេខ: +៨៥៥-១២ ៤៨៨ 0៩៤
ទូរសព្ទលើតុលេខ: +៨៥៥ (0) ២៣ ២១៩ ៨១៤
អ៊ីមែល: dim.sovannarom@eccc.gov.kh